01008798



ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 08 / 2014
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** សាធារណៈ / Public

ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤

**ជូនចំពោះ:** **ភាគីទាំងអស់ក្នុងសំណុំរឿង ០០២**

**ពី:** **និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សំណើរបស់ ខៀវ សំផន សុំការបំភ្លឺ និងការកែប្រែឧបសម្ព័ន្ធនៃសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀតក្នុងសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២**

អង្គជម្រះសាលាដំបូងបានទទួលសំណើមួយពីក្រុមមេធាវីការពារក្ដី ខៀវ សំផន សុំការបំភ្លឺ និងកែតម្រូវ ឧបសម្ព័ន្ធ ក នៃសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀតក្នុងសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ (E301/9/1.1/1)។ ជាពិសេស ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានកត់សម្គាល់ឃើញមានភាពខុសគ្នានៅក្នុងជើងទំព័រយោងលេខ ៩ ដែលនៅក្នុងអត្ថបទជាភាសាខ្មែរ និងភាសាអង់គ្លេស មានព័ត៌មាន តែមិនឃើញមានព័ត៌មានដូចគ្នានេះនៅក្នុងអត្ថបទជាភាសាបារាំង។ អង្គជំនុំជម្រះសូមបញ្ជាក់ថា អត្ថបទជាភាសាខ្មែរ និងភាសាអង់គ្លេស មានភាពត្រឹមត្រូវ ហើយអង្គភាពបកប្រែភាសាត្រូវបានស្នើឲ្យធ្វើការកែតម្រូវអត្ថបទជាភាសាបារាំងទៅតាមនោះ។ នេះគឺជាការឆ្លើយតបជាផ្លូវការពីអង្គជំនុំជម្រះចំពោះឯកសារ E301/9/1.1/1។